## ទីក្រុងឡុងប៊ិច
## ការវិភាគមិនលំអៀងរបស់មេធាវីក្រុង ចំពោះវិធានការ LBU

### វិសោធនកម្មធម្មនុញ្ញ ដើម្បីសម្រប/ស៊ីសង្វាក់តាមកាលបរិច្ឆេទនៃការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់ក្រុមប្រឹក្សាអប់រំក្រុងឡុងប៊ិច ជាមួយនឹងកាលបរិច្ឆេទបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់រដ្ឋ ដែលបានប្រព្រឹត្តទៅឡើងក្នុងឆ្នាំដែលមានលេខគូរ

នៅថ្ងៃទី 9 ខែសីហា ឆ្នាំ 2022 ក្រុមប្រឹក្សាក្រុងឡុងប៊ិចបានដាក់វិធានការ LBU នៅលើសន្លឹកឆ្នោត។ វិធានការនេះស្នើឱ្យធ្វើវិសោធនកម្មធម្មនុញ្ញទីក្រុងឡុងប៊ិច ដើម្បីស៊ីសង្វាក់តាមកាលបរិច្ឆេទនៃការបោះឆ្នោតបឋម កាលបរិច្ឆេទបោះឆ្នោតទូទៅរបស់ក្រុមប្រឹក្សាអប់រំក្រុងឡុងប៊ិច ("ក្រុមប្រឹក្សាសាលា") ជាមួយនឹងកាលបរិច្ឆេទបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់រដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងឆ្នាំដែលមានលេខគូរ។ ក្រុមប្រឹក្សាសាលា គ្រប់គ្រងតំបន់សាលាបង្រួបបង្រួមក្រុងឡុងប៊ិច ("LBUSD")។

ផ្នែកទី 2206 នៃធម្មនុញ្ញ បច្ចុប្បន្ននេះតម្រូវឱ្យក្រុមប្រឹក្សាសាលារៀបចំការបោះឆ្នោតបឋមរបស់ខ្លួន នៅថ្ងៃអង្គារអាទិត្យទីពីរ ក្នុងខែមេសានៅក្នុងឆ្នាំដែលមានលេខគូ ហើយការបោះឆ្នោតទូទៅរបស់ខ្លួននៅថ្ងៃអង្គារអាទិត្យដំបូង បន្ទាប់ពីថ្ងៃចន្ទ អាទិត្យទី 1 ក្នុងខែមិថុនាក្នុងឆ្នាំដែលមានលេខគូ។

ធម្មនុញ្ញ ផ្នែកទី 2204 បច្ចុប្បន្ននេះតម្រូវឱ្យបេក្ខជនដែលមានសិទ្ធិ ត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះដោយស្របច្បាប់ និងជាអ្នករស់នៅក្នុងសង្កាត់ក្រុមប្រឹក្សាសាលា ដែលបានតែងតាំងយ៉ាងតិចសាមសិប (30) ថ្ងៃភ្លាមៗ មុនថ្ងៃដំបូងដែលបេក្ខជនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំអោយធ្វើការតែងតាំងឬឈ្មោះ។

វិធានការនេះ នឹងធ្វើវិសោធនកម្ម ផ្នែកទី 2206 នៃធម្មនុញ្ញ ដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតបឋម និងទូទៅរបស់ក្រុមប្រឹក្សាសាលា ដើម្បីអោយស្របពេលជាមួយគ្នានឹងការបោះឆ្នោតបឋម និងទូទៅរបស់រដ្ឋ។ បច្ចុប្បន្ននេះ ការបោះឆ្នោតបឋមរបស់រដ្ឋ ប្រព្រឹត្តទៅនៅក្នុងខែមីនាសម្រាប់ឆ្នាំបឋមនៃការបោះឆ្នោតប្រធានាធិបតី និងនៅក្នុងខែមិថុនា សម្រាប់ការបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសរើសអភិបាលរដ្ឋឡើងវិញ។ ការបោះឆ្នោតទូទៅរបស់រដ្ឋប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា សម្រាប់ទាំងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងការបោះឆ្នោតជ្រើសរើសអភិបាលរដ្ឋឡើងវិញ។

វិធានការនេះ នឹងធ្វើវិសោធនកម្ម មាត្រាទី 2204 តម្រូវឱ្យបុគ្គលដែលបានចុះឈ្មោះបោះឆ្នោតដោយស្របច្បាប់ និងជាអ្នករស់នៅក្នុងសង្កាត់ក្រុមប្រឹក្សាសាលា ដែលបានតែងតាំងយ៉ាងតិចសាមសិប (30) ថ្ងៃ យ៉ាងតិចសាមសិប (30) ថ្ងៃ មុនថ្ងៃចុងក្រោយ ដែលបេក្ខជនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំអោយធ្វើការតែងតាំងឬឈ្មោះ។

ការបោះឆ្នោត "បាទ/ចាស" នឹងបណ្តាលអោយខោនធីឡូសអានជីឡេស ដំណើរការក្នុងការបោះឆ្នោតរបស់ក្រុមប្រឹក្សាសាលា ដែលនឹងមានផលប៉ះពាល់ដល់សារពើពន្ធ/ថវិការម្តងទៀត ដែលត្រូវបានប៉ាន់ប្រមាណថាមានចំនួនសរុប 1.15 លានដុល្លារ សម្រាប់ការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅ។

ការបោះឆ្នោត "ទេ" សម្រាប់វិធានការនេះ ទំនងជានឹងបណ្តាលឱ្យទីក្រុងដំណើរការការបោះឆ្នោតក្រុមប្រឹក្សាសាលា។ ផលប៉ះពាល់សារពើពន្ធសម្រាប់ការបោះឆ្នោត "ទេ" លើវិធានការនេះ គឺផ្អែកលើថាតើវិធានការបោះឆ្នោតរបស់ទីក្រុងត្រូវបានអនុម័តដោយអ្នកបោះឆ្នោត និងថាតើ LBUSD ចែកជួយរំលែកតម្លៃនៃការបោះឆ្នោតជាមួយទីក្រុងដែរឬទេ។ ផលប៉ះពាល់សារពើពន្ធអាចបណ្តាលឱ្យមានការចំណាយឡើងវិញ ដែលត្រូវបានប៉ាន់ប្រមាណនូវចំនួនសរុប ពី 2.75 លានដុល្លារ ទៅ 2.9 លានដុល្លារ សម្រាប់ការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅ និងការចំណាយតែម្តងចំនួន 2.5 លានដុល្លារ ដើម្បីទទួលបាននូវឧបករណ៍ផ្សេងៗ បរិក្ខារ និងបុគ្គលិកដែល

ត្រូវការសម្រាប់ទីក្រុង ដើម្បីដំណើរការនៃការបោះឆ្នោតក្រុមប្រឹក្សាសាលា។

ការបោះឆ្នោត "បាទ/ចាស" គឺជាគាំទ្រដល់ការបោះឆ្នោតរបស់ក្រុមប្រឹក្សាសាលា ដែលសម្របតាមកាលបរិច្ឆេទបោះឆ្នោតរបស់រដ្ឋ។

ការបោះឆ្នោត "ទេ" គឺក្រុមប្រឹក្សាសាលាប្រឆាំងជំទាស់ មិនសម្របការបោះឆ្នោតតាមកាលបរិច្ឆេទបោះឆ្នោតរបស់រដ្ឋ និងរក្សាកាលបរិច្ឆេទការបោះឆ្នោតក្រុមប្រឹក្សាសាលាដែលមានស្រាប់ អោយនៅដដែល។

តម្រូវអោយមានសំឡេងភាគច្រើន បោះឆ្នោត "បាទ/ចាស" ដើម្បីឱ្យវិធានការនេះអនុម័ត/ឈ្នះ។

**សេចក្តីថ្លែងការណ៍ខាងលើនេះ គឺជាការវិភាគមិនលំអៀងចំពោះវិធានការ LBU។ ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃវិធានការនេះ សូមទូរស័ព្ទទៅកាន់ការិយាល័យស្មៀនក្រុង តាមលេខ 562-570-6101 ហើយច្បាប់ចម្លងនេះ នឹងត្រូវបានផ្ញើទៅអោយអ្នកដោយឥតគិតថ្លៃ។**

CHARLES PARKIN
មេធាវីក្រុងឡុងប៊ិច